# ការសំភាសន៍របស់លោកពូ គុយ បាន

កះ អ្នកដែលសំភាសន៍ញ៉ែម សុគន្ធា ខះ អ្នកដែលត្រូវគេសំភាសន៍ គុយ បាន

## <u>ការសង្ខេបរបស់លោកពូ គុយ បាន</u>

លោកពូ គុយ បាន ជាអ្នកស្រុករកាកោង ហើយគាត់បានផ្លាស់ទីលំនៅមករស់នៅព្រែកហូរ លោកពូរៀបការជាមួយប្រពន្ធឈ្មោះ ជា សុខជា ហើយរៀបការមានកូនចំនួន៤នាក់ លោកពូធ្លាប់ធ្វើការជាកម្មករធ្វើឥដ្ឋការ៉ូហើយនឹងរត់តុកតុក ។លោកពូបានកើតទាន់សង្គ្រាម លន់ នល់ នឹងប៉ុល ពត ហើយគាត់នៅតូចពេលក្នុងរបបសង្គ្រាម ហើយការហូបចុកនៅក្នុងសង្គ្រាមប៉ុល ពតគឺមានការពិបាកខ្លាំងហើយមិនបានឆ្អែតគ្រប់គ្រាន់ឡើយ។

កះ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលបានអោយញ៉ុមសំភាសន៍អំពីជីវិតរបស់លោកពូហើយនាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកដែលសំភាសន៍អំពីជីវិតរបស់លោកពូនៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍គឺនៅក្នុងថ្ងៃទី២២ខែ មិនា ឆ្នាំ២០១៨ ហើយទីតាំងដែលពួកយេីសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ប្រទេសកម្ពុជា។ហើយនាងខ្ញុំសូមចាប់ផ្ដើមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូមានដូចតទៅ។ អ៊ិចឹងលោកពូសូមប្រាប់ឈ្មោះលោកពូលោកពូឈ្មោះអីគេដែរ?

ខះគុយ បាន។

កះ គុយ បាន?

ខះបាទ!!

កះសំរាប់លោកពូសព្វថ្ងៃលោកពូមានអាយុប៉ុន្មានឆ្នាំហើយ?

ខះ ញ៉ុម៤៦។

កៈ ៩៦ឆ្នាំ!!

ខៈបាទ!!

កៈលោកពូកើតឆ្នាំខ្មែរកើតឆ្នាំអីគេវិញ?

ខៈ ឆ្នាំខ្មែរឆ្នាំរកា។

កៈរកា!!អញ្ចឹងលោកពូសំរាប់អើរ លោកពូចាំថាខ្លួនឯងកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ ឆ្នាំដែលលោកពូកើតហាំ??

ខៈ អត់ ដឹងតែឆ្នាំ ដឹងតែអាឆ្នាំដូចថារកា រកាអ៊ីចឹងម៉ង អាថ្ងៃនោះអត់ដឹង។

កៈ ចាំ!!អត់ចាំថ្ងៃនោះទេពូហោ?

ខៈ បាទ!!

កៈ ពូអ្នកស្រុកមកពីណាវិញ?

ខៈ ញុំមមកពីខាងទន្លេហ្វំ!!

កៈ គេហៅភូមិអីគេវិញពូ?

ខៈ នៅខាងរកាកោង។

កៈ ហ្វំ នៅខាងរកាកោង នៅខាងខេត្តកណ្ដាលយើងតើពូហោ?

ខៈ រកាកោងខេត្តកណ្ដាល ។

កៈ គេហៅភូមិឃុំអីគេដែរពូអាហ្នឹង?ពូអត់ចាំភូមិឃុំអីណាហី?

ខៈ ហ្នឹងហើយភ្លេចបាត់ហើយ!!

កៈ លោកពូកើតមកធំធាត់នៅរកាកោងហ្នឹងម៉ងលោកពូហោ?

ខៈ ហ្នឹងហើយ។

កៈ លោកពូក្រៅពីឈ្មោះបានលោកពូមានឈ្មោះអីគេផ្សេងទៀតទេ?

ខៈ អត់ទេ តែមួយហ្នឹងរហូត។

កៈ តែមួយហ្នឹងរហូត
!!អត់ដែលមានអ្នកណាគេដាក់ងារអីផ្សេងអោយក្រៅពីហ្នឹងអីទេលោកពូហេ?

ខៈ អត់ទេ។

កៈ លោកពូ សំរាប់លោកពូមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ ប្រុស៣ស្រី២។

កៈ ហើយលោកពូជាកូនទីប៉ុន្មានវិញ?

ខៈទី៣។

កៈ លោកពូចាំឈ្មោះបងប្អូនលោកពូទាំងអស់អត់?

ខៈ ចាំតើ!!

កៈ គាត់ឈ្មោះអីគេខ្លះពូអាចប្រាប់តាំងពីបងគេរហូតដល់ពៅគេបានពូណាស់?

ខៈ បងគេគុយ បាវ ។

កៈ បងគេឈ្មោះគុយ បាវ តែម្តង??

ខៈ ហ្នឹងហើយ។

កៈ ដល់ពេលបន្ទាប់ទៀតលោកពូ?

ខៈ គុយ សារឿន។

កៈ ហើយដល់ទី៣?

ខៈ ហើយទី៣ខ្ញុំនឹងហើយ គុយ បាន។

ក៖ហើយ៣នាក់ទៀតហ្ន៎?

ខ៖ ២នាក់ទៀតគុយ បូ ហើយនឹងគុយ សុខលី។

ក៖ ៦នាក់ឬក៏៥នាក់?

ខ៖ ៥។

ក៖
៥ទេហោទេហោហ្នឹងហើយ!!លោកពូបងប្អូនលោកពូគាត់រស់នៅទាំងអស់ឬក៏មានអ្នកខ្លះអនិច្ចាកម្ម?

ខ៖ អត់ទេរស់ទាំងអស់។

ក៖ នៅរស់ទាំងអស់ហោ!!អញ្ចឹងបងប្អូនលោកពូឥឡូវគាត់រស់នៅឯណាខ្លះទៅ?

ខ៖ នៅស្រុកកំនើតទាំងអស់ ចេញមកឆ្ងាយតែខ្ញុំមួយ។

ក៖ ចាំ!!លោកពូដូរមកនៅព្រែកហូរនេះតាំងពីឆ្នាំណាមកវិញ?

ខ៖ ហ៊ុយូរហើយភ្លេចបានហើយ។

ក៖ ចាំ!!អញ្ចឹងនិយាយពេលហ្នឹងពេលបែកសង្គ្រាមហើយមែនលោកពូបានមកនៅទីនេះ?

ខ៖ អត់ទេទឹមតែមកនៅហ្នឹង!!

ក៖ ទឹមមកនៅដែរទេហោ!! លោកពូមានរៀបការជាមួយប្រពន្ធគាត់ឈ្មោះអីគេដែរ?

ខ៖ ជា សុខជា។

ក៖ ចាំ អ្នកមីងនៅរាល់ថ្ងៃតើលោកពូហោ?

ខ៖ បាទនៅនឹងតាខ្មៅយើងហ្នឹង!!

ក៖ តែគាត់អត់មកនៅជាមួយពូណាពូហោ?

ខ៖ គាត់មកនៅហ្នឹង តែពីមុនគាត់នៅតាខ្មៅ។

កៈ ចាំពេលមុននៅតាខ្មៅ!!តែឥឡូវនៅរួមរស់ជាមួយពូហោ?

ខៈបាទ!!

កៈ ឥឡូវអ្នកមីងគាត់ធ្វើការដែរហើយមែនទេលោកពូណេះ?

ខៈ ហ្នឹងហើយ។

កៈ គាត់ធ្វើការអីគេវិញលោកពូ?

ខៈ លក់នំ។

កៈ គាត់ជិះកង់ដើរលក់រាល់ថ្ងៃវិញឬក៏ម៉េច?លក់នៅណាវិញទៅលោកពូ?

ខៈ លក់នៅផ្សារច្បារអំពៅ។

កៈចាំ!!

ខៈទៅពីហ្នឹងទៅជិះរម៉ក់ទៅ។

កៈ ចាំហ្នឹងហើយ អញ្ចឹងលោកពូ លោកពូចាំអីគេខ្លះពីបងប្អូនហាំ
លោកពូធ្លាប់លេងអីគេខ្លះជាមួយបងប្អូនដែរ?

ខៈ ហ៊ឺភ្លេចអស់ហើយយូរហើយ។

កៈ ចាំ ឥឡូវពួកគាត់ទាំងអស់គ្នាហ្នឹងរកស៊ីនៅណាវិញដូចជារកស៊ីអីគេខ្លះវិញពូចាំទេ?

ខៈ ពួកហ្នឹងគេសុទ្ធតែមេជាងសំនង់មេអី!!

កៈចាំ!!

ខៈធ្វើនៅតែស្រុកពួកហ្នឹងមិនដែលមកភ្នំពេញទេ!!

កៈចាំ!!លោកពូ ចុះសំរាប់ឥឡូវលោកពូប្រកបរបរអីគេដែរ?

ខៈ ញ៉ុមពីមុនរត់អាកង់៣ឥឡូវលក់អាកង់៣ទៅ
ថារកទិញវិញមួយថ្ងៃជៀសមួយថ្ងៃនៅហ្នឹងៗ!!

កះចាំ!!អញ្ចឹងលោកពូឥឡូវហ្នឹងនៅផ្ទះសិនលោកពូហោ?

ខះ ហ្នឹងហើយ។

កះ លោកពូមានម្ដាយឈ្មោះអីគេដែរ គាត់?

ខះ ម្ដាយឈ្មោះយី ឡាយ តែគាត់ស្លាប់ហើយ។

កះ ចាំគាត់ស្លាប់ដោយសារជំងឺអីគេដែរលោកពូ ម្ដាយ?

ខះ ជំងឺមនុស្សចាស់។

កះ ហ្ហ៎អ៊ីចឹង!!

ខះ គាត់៦០ជាងហើយ!!

កះចាំ!!អញ្ចឹងមុនគាត់ស្លាប់គាត់ឈឺដែរលោកពូណោះ?

ខះ ឈឺ!!

កះ ចាំ លោកពូពេលដែលម្ដាយលោកពូនៅរស់ គាត់ធ្វើការអីគេដែរ?

ខះ អ្នកស្រែធម្មតា។

កះដាំស្រូវដាំអីអញ្ចឹងទៅពូណោះ?

ខះ ហ្នឹងហើយ ដាំស្រូវល្ងអីហ្នឹង។

កះកូនមែនលោកពូ?(សួរកូនគាត់ទើបតែដើរមក)

ខះកូន!!

កះ ហ្នឹងហើយ។ លោកពូលោកពូចាំអីគេខ្លះពីម្ដាយដែរ
ម្ដាយគាត់ជាមនុស្សបែបណាដែរអ៊ីចឹងហាំ?អត់ចាំណាលោកពូហោ?

ខះ អត់ចាំទេ!!

កៈ គាត់ស្លាប់ចោលលោកពូប៉ុន្មានឆ្នាំហើយលោកពូ?

ខៈ ប៉ុន្មានឆ្នាំហើយនេះហិ តាំងពីញ៉ុមនៅ មុខផ្សារតាខ្មៅថ្មីហ្នុំ!!

កៈ ហ្នុំអ៊ិចឹងយូរឆ្នាំដែរហើយ!!

ខៈ តាំងពពេលផ្សារតាខ្មៅថ្មីគេមិនទាន់ធ្វើណោះ។

កៈហ្នុំ!!ហ៊ើយូរហើយពូណាស់!!

ខៈ បាទគាត់ស្លាប់តាំងពស្រេបក់ហ្នឹង។

កៈ ហ្នឹងហើយ ចង់ចូល១០ឆ្នាំជាងហើយពូហោ?

ខៈហ្នឹងហើយ។

កៈអ៊ិចឹងពូសំរាប់ឪពុករបស់ពូគាត់ឈ្មោះអីគេដែរ?

ខៈ រស់ គុយ។

កៈចាំ អ៊ីចឹងលោកពូយកឈ្មោះរបស់គាត់ដាក់ជាត្រកូលហ្នឹង?

ខៈ ហ្នឹងហើយ។

កៈ គាត់អនិច្ចាកម្មឬក៏គាត់នៅរស់លោកពូ?

ខៈ អនិច្ចាកម្មបាត់ហើយ។

កៈ ចាំមុនឬក៏ក្រោយម្ដាយ?ខៈមុន!!កៈ មុនទៀតហោ?គាត់ស្លាប់មូលហេតុអីគេដែរលោកពូ?

ខៈ ប៉ាជំងឺមនុស្សចាស់។

កៈ
សុទ្ធតែជំងឺមនុស្សចាស់ពូណោះ?ខៈបាទ!!កៈម្ដាយរបស់លោកពូគាត់អ្នកស្រុកមកពីណាដែរលោកពូ?

ខៈ គាត់ស្រុកកំនើតគាត់នៅទន្លេហ្នឹងម៉ង!!

កៈ ចាំនៅខាងរកាកោងហ្នឹង!!ចុះឪពុកវិញលោកពូ?

ខៈ ឪពុកនៅខាងហ្នឹង។

កៈ ខាងហ្នឹងដូចតែគ្នា?ចាំ!!លោកពូឪពុកហើយនឹងម្ដាយគាត់រកស៊ីអីគេដែរដើម្បីចិញ្ចឹមពូហា?

ខៈ គាត់ធ្វើជាងផ្ទះ។

កៈ ទាំង២នាក់តែម្ដងឬក៏តែឪពុកទេ?

ខៈ តែឪពុកទេ។

កៈចុះម្ដាយគាត់ធ្វើអីគេវិញលោកយាយ?

ខៈ ធ្វើស្រែចំការធម្មតាយើង។

កៈ
ចាំ!!លោកពូសំរាប់តាយាយខាងម្ដាយហាំគាត់ឈ្មោះតាអីគេដែរ?ឪពុករបស់ម្ដាយរបស់លោកពូហាំ??តាខាងម្ដាយហ្ហ៎??

ខៈ តាខាងម្ដាយហេ?

កៈចាំ!!គាត់ឈ្មោះអីគេវិញ?

ខៈ យី ឡាយ។

កៈ យីឡាន!!ចុះយាយ?

ខៈ យាយយាយសាយ។

កៈលោកពូកើតទាន់យាយទាំងពីរនាក់តើហី?

ខៈ អត់ទាន់ទេ។

កៈ គាត់ស្លាប់ពេលណាវិញពូ?

ខៈ គាត់ស្លាប់មុនជំនាន់លន់ នល់ ប៉ុន្មានសិបឆ្នាំណោះ!!

កះ ហ្ហ៎អញ្ចឹងយូរណាស់ដែរហើយហ្នឹងអញ្ចឹង!!

ខះបាទ!!

កះ អ៊ីចឹងលោកពូអ៊ីចឹងតាយាយខាងម្ដាយហា៎ គាត់អ្នកស្រុកមកពីណាវិញ?

ខះ គាត់នៅហ្នឹងទាំងអស់គ្នានៅហ្នឹងម៉ងហ្នឹង។

កះ អ្នកទន្លេហ្នឹងដែរ?

ខះ បាទ!!

កះ ចុះពូតាយាយខាងឪពុកគាត់ឈ្មោះតាអីយាយអីគេដែរ?

ខះតាយាយខាងឪពុកអត់ចាំអត់ស្គាល់ទេ!!

កះ ពូកើតអត់ទាន់ហេ?

ខះ បាទ!!

កះ ដល់ពេលអ៊ិចឹងគាត់ស្លាប់ទៅ!!

ខះ តែឪពុកម្ដាយញ៉ុមហ្នឹងញ៉ុមអត់ទាន់ផង។

កះចា៎!!អ៊ីចឹងលោកពូលោកពូអាចនិយាយពីជំនាន់លន់ នល់ហា៎ហើយនឹងប៉ុល
ពតអីវ៉ានទាំងអស់អីវ៉ាន់ទាំងអស់ហ្នឹងហេ?

ខះទាន់តើ!!

កះចា៎!!

ខះលន់ នល់ក៏ទាន់ប៉ុល ពតក៏ទាន់។

កះ អញ្ចឹងពូអាចនិយាយពីជីវិតពូពេលជំនាន់លន់ នល់តើពូជួបរឿងអីគេខ្លះ?

ខះ ហេជំនាន់លន់ នល់ នៅតូចណាស់!!

កៈ ម៉េចវិញទៅពូ?

(មិត្តភក្តិ)ៈជំនាន់លន់ នល់ វាធ្វើឆ្លប។

កៈ ជំនាន់លន់ នល់ ណាមានទាន់មានឆ្លប អត់ទាន់ទេហី?ខៈនៅ!!

(មិត្តភក្តិ)ៈ ជំនាន់ លន់ នល់ វានៅរៀនហ្នឹង។

កៈហ្ហ៎!!

ខៈ លន់ នល់ នៅតូចណាស់!!

កៈ ពូមានដែលឃើញគេទំលាក់គ្រាប់គេទំលាក់អីអត់?

ខៈអត់!!

(មិត្តភក្តិ)ៈនិយាយមិនឃើញម៉េចខាងហ្នឹង!!ខាងកោះច្រាំងនៅស្រុកញ៉ុមហ្នឹង!!

កៈចា៎!!

ខៈទំលាក់ពេញទំហឹងហើយជំនាន់ហ្នឹងហ្ហ៎!!កន្លែងដែលសំខាន់បំផុតព្រៃកតាម៉ែក ព្រៃកតាមឹម ព្រៃកអញ្ចាញ់ហ្នឹង។

កៈចា៎!!

ខៈហ្នឹងហើយ!!

កៈ
ហើយពូមានដែលធ្លាប់ជីកត្រង់សេអីវ៉ាន់ដូចថាឪពុកម្តាយគាត់ធ្វើមួយហ្នឹងដើម្បីគេចគ្រាប់គេចអីអត់?

ខៈ ធ្លាប់តើ!!

កៈ តែបើសិនជាទំលាក់មកចំត្រង់សេហ្នឹងក៏នេះដែរហី ក៏ស្លាប់ដែរ!!

(មិត្តភក្តិ)ៈខ្មេច។

កះខ្មោចម៉ង!!

ខះ ខ្មោចមួយត្រង់សេហ្នឹងអីចឹង!!

(មិត្តភក្តិ)ះចុះឬស្សីជ្រោយអីមួយគ្រាប់មកខ្មោច!!មួយគ្រាប់ខ្មោចតែម្តង ខ្មោចតែម្តង!!

(មិត្តភក្តិម្នាក់ទៀត)ះ កំពុងជីកហ្នឹងហាំ!!វារាកៗៗមកវានៅក្រោយផ្ទះ
លោតចូលទាំងអស់គ្នាអាទូចៗ!!

ខះ ពេលហ្នឹងអាអ្នកអត់ត្រូវគេក៏ត្រូវគ្នាវិញដែរ!!កាលពេលជំនាន់ហ្នឹង!!ហើយសំរុកចូលទៅ!!

(មិត្តភក្តិម្នាក់ទៀត)ះ សំរុកទៅចូលជាន់គ្នា។

ខះ ជាន់គ្នាអាខ្លះអត់និយាយរកគ្នាក៏រត់ចូលដែរ!!

(មិត្តភក្តិ)ះក្អួយចង្កៀងហាំ ក្នុងអាដេញគេមិនមែនហៅមាត្រដ្ឋាន
អាហ្នឹងគេត្រង់ហៅត្រង់សេហាំ!! ហ្នឹងហើយសរសេរសុទ្ធតែប៉ុណ្ណឹងហិ!!
ដាក់ពីលើអុជក្រោមដីហើយចង្កៀងអុជក្រោមហ្នឹងហិ!!កះចាំ!!ខះបាយទឹកហ្នឹងក្នុងហ្នឹងអត់មា
នហ៊ានចេញទេ!!ពេលអាម៉ារីនឡើងអញ្ចឹងមក
អាហ្នឹងគេគោះជួងហើយណាស់!!នាំគ្នាចូលអស់រលីង។

កះចាំ!!

ខះបាយហ្នឹងដេកហ្នឹងអីហ្នឹង!!

កះ ហើយដកដង្ហើមរួចដែរតើពូហេ ដូចរបៀបថានៅក្នុងត្រង់សេហ្នឹង?

(មិត្តភក្តិ)ះ អត់ទេយើងមានគំរប!!គំរបសងខាង។

ខះ គំរបគេធ្វើគំរបសងខាង!!

កះហ្ហ៎!!

(មិត្តភក្តិ)ះ យើងលង់ដី យើងលង់ដីធំណាស់!!

កះ ចាំ!!(មិត្តភក្តី)ះ ហ្នឹងហើយ។

(មិត្តភក្តិម្នាក់ទៀត)៖ គេលង់បត់បត់!!

(មិត្តភក្តិ)៖ គេលង់មាត់មានសងខាងហ្នឹងហើយ!!

ខ៖ ចង់១៥!!

(មិត្តភក្តិ)៖ ក្រាលកន្ទេលក្រាលអីដេកនៅហ្នឹងអីហ្នឹង ចង្កៀងអាកាទឹបប្រេងកាតហ្នឹង!!

ក៖ ហើយដល់ពេលអញ្ចឹងនៅក្នុងហ្នឹងអញ្ចឹងម៉ងទៅ!!

(មិត្តភក្តិ)៖ វាប្អូនញ៉ុម!!

ខ៖ ១៥ ត្រង់សេមួយ១៥នាក់ ២០នាក់!!

ក៖ចាំ!!ចុះលោកពូដល់ពេលចូលដល់ជំនាន់ប៉ុល ពតម្តងហា!!តើលោកពូម៉េចដែរ?

ខ៖ ជំនាន់ប៉ុលពត!!

ក៖ មើលលោកពូរៀបរាប់ជីវិតពីពេលជំនាន់ប៉ុល ពតអោយបានក្បោះក្បាយមើល??

ខ៖ នេះអារៀបរាប់នេះ!!

ក៖អត់ទេពូគាត់នេះ សួរពីជីវិតពូសិន ចាំតិចទៀតចាំសួរពីជីវិតពូក្រោយ?

ខ៖ សួរវាមុនទៅ!!

ក៖តពូពូសិន!!អោយចប់ពូមួយសិន។

(មិត្តភក្តិ)៖ ហ្អែងមិនរៀបរាប់ពីជំនាន់ប៉ុល ពតហ្អែងធ្វើអីគេខ្លះ?កុមារ ហ្អែងកងចល័តហីក៏ស្អី?

ខ៖ ជំនាន់ប៉ុល ពតអញធ្វើមេខ្មែរក្រហម!!

(មិត្តភក្តិ)៖ អាគេបាញ់!!

ក៖ពូមែនមិនមែនធ្វើមេខ្មែរក្រហម?

ខ៖ ហ៊ឺ!!

(មិត្តភក្តិ)៖ មេស្អីវានៅក្មេងហ្នឹង!!

ក៖ហ្ហ៎ !!ពូធ្វើការអីគេខ្លះនៅក្នុងហ្នឹង?

ខ៖ ហ៊ីកុមារគេអោទូលអាចមន៍គោហ្នឹង!!

(មិត្តភក្តិ)៖ ហ្នឹងហើយត្រូវវានិយាយ និយាយត្រូវ!!

ក៖ តែបើអោយធ្វើមេខ្មែរក្រហម!!

ខ៖ អោយតែពុជូងពឹងនឹងអាលរត់ជាន់គ្នា!!

ក៖ ប៉ុននេះទេពូ?

(មិត្តភក្តិ)៖ អត់ទេធំជាងហ្នឹងបន្តិច។

ខ៖ ត្រើស!!

ក៖ ត្រើសដែរហោ?

ខ៖ ត្រើសជាងហ្នឹង!!

ក៖ ចាំអាយុប៉ុន្មានដប់ពេលនៅក្នុងជំនាន់ហ្នឹង?

ខ៖ ហោ!!អត់ដល់ដប់ទេ ប្រហែលជាខ្ទង់១០ឆ្នាំចុះក្រោម។

ក៖ ហ្ហូតិចដែរហ្នឹងអ៊ីចឹងហ្ហ៎!!

ខ៖ អាយុតិចដែរហ្នឹងអ៊ីចឹង!!

ក៖ចាំអញ្ចឹងពូម៉េចដែរនៅក្នុងជំនាន់ប៉ុល ពតការហូបចុករបស់ពូ?

ខ៖ មានអីឆ្ងាញ់ដែរតើ!!បបរសរ!!

(មិត្តភក្តិ)៖ មួយវែកអីទៅអញ្ចឹង។

ក៖មួយវែកអញ្ចឹងទៅពូហោ?

ខ៖ បាទហ្នឹងហើយមួយរែក បានតែអាបបរសរហ្នឹងគ្រាន់ហើយ!!អាបបរ

(មិត្តភក្តិ)៖ បបរលែងត្រកួនទៀត។

ខ៖ដាក់ត្រកួន គ្រាប់ពោត!!

(មិត្តភក្តិ)៖ គ្រាប់ពោតយើង!!

(មិត្តភក្តិម្នាក់ទៀត)៖ អាគ្រាប់ពោតសាលីយើងហ្នឹង!!

ក៖ ពូកំប្លែងស្ងួតម៉ងហាំ!!មុខអត់សើចអត់ញញឹមអីគេទេ ប៉ុន្តែកំប្លែងស្ងួត!!

ខ៖ បើនៅខាងឯងវិញបបរអោយគ្នាហូបបបរហ្អែងទាំងមូល គ្រាប់ពោតហាំ!!

ក៖ចាំ!!ចំគ្រាប់ពោតអត់មានកិនអត់មានអីទេហេ ដាក់ទំាងមូលអញ្ចឹងម៉ង?

ខ៖ ហ្នឹងទាំងមូលទាំងមូល។

ក៖ ចាំពូម៉េចដែរពេលខ្លះ ពេលខ្លះមានបានហូបឆ្អែតមានបានហូបអីអត់ទេពូ?

ខ៖ មួយឆ្នាំមិនទាន់បានឆ្អែតម្តងផង!!ហាបានឆ្អែតម្តងម្កាលអីដែរ!!

ក៖ពេលហ្នឹងគេមានបុណ្យទាន់អីមែនបានគេបានឆ្អែតម្តងពូ?

ខ៖ បានឆ្អែតគេ!!

(មិត្តភក្តិ)៖ ថ្ងៃ២០ ថ្ងៃ៣០បានឆ្អែត។

ខ៖ ហ្នឹងហើយ!!

(មិត្តភក្តិ)៖ ថ្ងៃទី១០បារាំង ថ្ងៃ២០ ថ្ងៃ៣០។

ក៖ហ្នំអាមានថ្ងៃគត់ៗអញ្ចឹងគេមាថ្ងៃអោយហូបឆ្អែតអ៊ីចឹងដែរ?

(មិត្តភក្តិ)៖ហ្នឹងហើយ!!

ខ៖ហ្នឹងហើយ។

(មិត្តភក្តិ)៖មួយខែ៣ដង
បើមិនអញ្ចឹងទេបាញ់ជំនឿកអីអីចឹងទៅ!!ក៖ហ្ហ៎!!(មិត្តភក្តិ)៖ភាគច្រើនតែបាញ់ជំនឿកហ្នឹង!!

(មិត្តភក្តិ)៖ អត់ទេអាហ្នឹងដោយតាមថ្ងៃនេះគេនេះទេ ដោយតាមខេត្តដែរទេ!!

ខ៖ តាមកន្លែងហ៎ា អាខ្លះគេអត់អត់ដែល!!

(មិត្តភក្តិ)៖មូលៗដាក់ក្នុងពាងអ៊ុងហ៎ា!!

ក៖ តាមពិតដូចគេសំបូរសប្បាយតើពូហី តែសំបូរអីហូបតើហី?

(មិត្តភក្តិ)៖សំបូរស្អីក្មួយហើយ!!

(មិត្តភក្តី)៖អត់សំបូរទេ!!

(មិត្តភក្តិ)៖អាផ្លាកយើងប៉ុណ្ណឹងហ៎ា អាឆ្នាំរោង
ញ៉ុមរុញក្បូនធ្វើដើមចេកហ៎ា!មកដួសម៉ាផ្លាកអីចឹងទៅខ្ញុំអត់ស៊ីទេអោយបងប្អូនអីម៉ែខ្ញុំអីហូប
ទៅប៉ុន្តែវែកហ្នឹង!!

(មិត្តភក្តិ)
៖ក្នុងមួយខ្ទះបបរពាក់ប៉ុងហ្នឹងហេ!!!ហើយដូចតិចចេកចំការយើងតិចទៅកាប់អាដេញយកមក
ស្ងោរស៊ីអីឆ្លបមកឃើញហ្នឹងងាប់ទៀត!!មិនបានទេ!!

(មិត្តភក្តិ)៖ ផ្កាត្រគៀតបេះដាក់នឹងហោប៉ាវក៏វ៉ែដែរ!!

ក៖ គ្រាន់តែផ្ការក្នុងស្រែសោះហ្នឹង!!

(មិត្តភក្តិ)៖ ខ្ញុំហ៎ាគ្រាន់តែផ្លែក្រូច ផ្លែក្រូចមួយសោះហ៎ា!!មួយហ៎ាស្អុយណាស់
គ្រាន់តែប៉ះស្អុយតិចឆ្លបគេលេងបណ្តោយ!!!ផ្លាច់ផ្លាច់ៗៗបានតាសិប្បកម្មតាត្បាញ
ត្បាញបង្កីបាញ់អីហ្នឹងហ៎ា!!ផ្តួករនាស់ផ្តួកដាក់ញ៉ុមម៉ង ប៉ិសរបួត កុំបានតែតាៗហ្នឹងជួយ
ថាក្រូចហ្នឹងស្អុយទេក្មួយអើយក្មួយបានរួចខ្លួន។

ក៖ ចាំអញ្ចឹងក៏រួចទៅ?

(មិត្តភក្តិ)៖ប៉ិសទៅ។

កៈ ចុះពូមានដែលគេចង់យកទៅកសាងឬក៏អីអត់អញ្ជឹង?

ខៈ អត់ទេ។

កៈ អត់អីដែរហោ?

ខៈហ្នឹងហើយ!!

កៈ ពូបងប្អូនពូពេលដែលគាត់នៅក្នុងជំនាន់ប៉ុល
ពតហ្នឹងមានគេដែលអ្នកណាយកទៅសម្លាប់ចោលអីអត់?

ខៈ អត់ទេអត់មានទេ!!

កៈ អត់មានដែរហោ?ពូពេលនៅជំនាន់ប៉ុល ពតពូនៅខាងខេត្តណាវិញ?

ខៈ ខេត្តកណ្តាលយើងហ្នឹងតែញ៉ុមនៅអាជួរមាត់ទន្លេហ្នូ!!

កៈជួរមាត់ទន្លេ?

ខៈ ជួរមាត់ទន្លេ!!

(មិត្តភក្តិ)ៈជួរមាត់ទន្លេអីមានអំពៅហូបហើយ!!

ខៈ មាត់ទន្លេនៅរកាកោងយើងហ្នឹង!!

កៈ អ៊ីចឹងនៅខាងទន្លេអីហ្នឹងសំបូរអីហូបអីអញ្ជឹងហើយពូណេះ?

ខៈបាទសំបូរ តែសំបូរ ដូចតែអត់សំបូរដដែលហ្នឹង!!

(មិត្តភក្តិ)ៈអ្នកណាអោយយើងហូបអត់ហ្នឹងហា៎!!

ខៈវាដាំបានប៉ុន្តែវាមិនអោយហូប!!

កៈ ចាំពូដែលឃើញនេះអត់
ដែលឃើញមានអ្នកណាគេសម្លាប់មនុស្សអីអត់?ពូមានដែលជួបអីអត់?

ខៈញ៉ុមអត់ដែលជួបផ្ទាល់ភ្នែកទេ!!

កៈតែគ្រាន់តែឮគេនិយាយថាម៉េចដែរ?ខៈបាទ!កៈដែលឮគេនិយាយតើពូណោះ?

ខៈហ្នឹងហើយ។

កៈតែពូពេលឮគេនិយាយហ្នឹងគេនិយាយថាម៉េចទៅពូ?របៀបថាសម្លាប់មនុស្សម៉េចដែរ?

ខៈ ឮសូរតែសំលេងអីចឹងហាំ!!ម៉ោង៨ ៩អីចឹងទៅជូនកាលដឹកគ្នា
អាកោះកន្លែងញុំមធ្វើចំការហ្នឹង។

កៈ ម៉េចដែរពូសំបូរគេសម្លាប់ពូហោ?

ខៈ សំបូរ!!

កៈ ពូដល់ពេលអញ្ចឹងម៉េចដែរ?បែកពីជំនាន់ប៉ុល
ពតមកមួយៗម៉េចដែរក្នុងអារម្មណ៍ពូម៉េចដែរបានផុតពីសង្គ្រាមអីចឹងណាស់?

ខៈ អូយ!!សប្បាយណាស់។

កៈ ពូចាំអាថ្ងៃចុងក្រោយនៃជំនាន់ប៉ុល
ពតហ្នឹងវាម៉េចដែរសំរាប់ជីវិតរបស់ពូហា?ដូចពេលយួនចូលមកហ្នឹងពូម៉េចដែរ?

ខៈ ពេលយួនរំដោះអញ្ចឹងយើងសប្បាយណាស់!!

(មិត្តភក្តិ)៖ ភ័យតើ!!

កៈភ័យម៉េចវិញទៅ?

(មិត្តភក្តិ)៖ កាល៧៥(១៩៧៥)លើកទង់សរណាស់ លើកទង់សរទំនប់ថ្មីនេះ
លើកទង់សរដើរហាំ!! អាហ្នឹងដល់ហើយគេរបៀបថា
យើងលើកទង់សរទៅរបៀបគេថាយើងចុះចាញ់គេ
គេអត់ធ្វើអីទេ!!អាហ្នឹង៧៥(១៩៧៥)ជិតបែកអាពតចូលហាំ!!

កៈចាំ!!(មិត្តភក្តិ)៖ដល់ពេល៧៩(១៩៧៩)ដល់ពេលវៀតណាមចូលនេះភ័យដែរតែគ្រាន់តែនៅ
ក្នុងត្រង់សេហ្នឹង។

កះចាំ!!

(មិត្តភក្តិ)៖តែអុំនោះគាត់ចេះវៀតណាមហ្នំ!!ចេះវៀតណាមគាត់ថាអត់មានទេ អត់មានស្អីទេ គាត់និយាយអីចឹងណាស់!!

កះចាំ!!តែពូដល់ពេលពួកវៀតណាមចូលមកមានអារម្មណ៍ម៉េចដែរគេគិតថា ពូគិតថាគេមកជួយឬក៏សង្គ្រាមមកបន្ថែម?

ខះ វាខ្លាចតែមកសម្លាប់មួយនិយាយអញ្ចេកពីរនិយាយអញ្ចុះនោះវៀតណាម!!

កះ គេនិយាយថាម៉េចដែរពូ ភាគច្រើនពួកប៉ុល ពត គេ ដូចនេះយើងម៉េចដែរ ពួកវាប្រាប់ថាយើងម៉េចដែរ?

(មិត្តភក្តិ)៖ថារំដោះ តែយើងវាអត់ទុកចិត្ត។

ខះយើងវាមិនទុកចិត្តព្រោះអាមួយខ្មែរយើងអាមួយគេវៀតណាមអីអីចឹងទៅ!!

(មិត្តភក្តិ)៖ ឃើញអីចឹងភ័យ!!យើងខ្មែរយើងភ័យឃើញវៀតណាមយើងភ័យតើ!!

កះចាំ!!

ខះភ័យហាំដំបូងៗយើងភ័យហាំ!!

(មិត្តភក្តិ)៖ដំបូងៗយើងឡើងរឹងខ្លួនអស់ហើយ!!

កះហ៊ឺៗ!!ខ្លាចដូចទ័ពប៉ុល ពតទៀត!!

(មិត្តភក្តិ)៖ ហ្នឹងហើយ!!

កះចុះដល់ពេលពួកវៀតណាមមកពួកប៉ុល ពតវ៉ៃគ្នាជាមួយអីចឹងទៅពូ?

(មិត្តភក្តិ)៖ វ៉ៃ វ៉ៃតើ!!

ខះវ៉ៃគ្នាវៀតណាមហើយប៉ុល ពតវ៉ៃគ្នាតើ!!

(មិត្តភក្តិ)៖ វ៉េតើ‼និយាយទៅយើងរត់ចេញពីភូមិយើងទៅនៅភូមិផ្សេងបាទ ក្រាំងញ៉ូវហ្នឹងបាទ តែយើងមើលឃើញភូមិយើងទេណាស់‼កាំភ្លើងបាញ់ភូងទៅភូងមកតគ្នា‼

ក៖ចាំ‼

(មិត្តភក្តិ)៖ យើងមកពីនោះមកឃើញភ្លើងឆេះអញ្ចឹងទៅណាស់‼

ក៖ អញ្ចឹងពូពេលបន្ទាប់បែកពីជំនាន់ប៉ុល ពតមកម៉េចដែរ?

ខ៖ ហ៊ីនៅរៀន។

ក៖ នៅរៀនតទៀតពូហេ?

ខ៖ នៅរៀន !

ក៖ ពូរៀនបានថ្នាក់ទីប៉ុន្មានវិញ?

(មិត្តភក្តិ)៖ ឌីផ្លូមហីហ្អែងហី?

ខ៖ញ៉ុមរៀនបានឌីផ្លូម។

ក៖ហ៊ីឡូយដែរតើបានឌីផ្លូមហើយ‼ពេលហ្នឹងបានធ្វើគ្រូធ្វើអីទេពូបានប្រលងអីហើយ?

ខ៖ វាមិនបានទេប្រលងឌីផ្លូមហើយរត់ទាហានចង់ងាប់ហើយ‼

ក៖ ពូមានគេចាប់បានទេ?ចាប់ទាហានទេ?

(មិត្តភក្តិ)៖ ទៅហីវានៅតែជង្រុកស្រូវ។

ខ៖ ពួនលើផ្ទះលើដំបូលផ្ទះវិញ។

ក៖តែគេចាប់អត់បានណាពូណេះ?

ខ៖អត់ដែលចាប់បាន។

ក៖ហើយពូដល់ពេលពូរៀបការមក រៀបការជាមួយមីងគាត់ឈ្មោះអីគេមិញ?

ខ៖ ជា សុខជា!!

ក៖ជា សុខជា?

(មិត្តភក្តិ)៖អាគុយ បាន!!

ក៖អត់ទេប្រពន្ធគាត់!!ពូរៀបការជាមួយប្រពន្ធមានកូនប៉ុន្មាននាក់ដែរ?

ខ៖កូន៤នាក់។

ក៖សព្វថ្ងៃកូនពូនៅជាមួយពូទាំងអស់ឬក៏បែកខ្លះហើយ?

ខ៖នៅទាំងអស់។

ក៖គាត់រៀបការខ្លះនៅកូន?

ខ៖ រៀបការបានមួយ។

ក៖ចាំពូចាំឈ្មោះកូនទាំងបួននាក់គាត់ឈ្មោះអីគេខ្លះអញ្ចឹងណាស់?

ខ៖ អាបងនោះឈ្មោះ បាន ពីសិដ្ឋ។

ក៖ ចាំដល់ពេលកូនទី២?

ខ៖ ទីពីរ បានវិសាល។

ក៖ ដល់ពេលកូនទី៣?

ខ៖ ទីបីបាន បញ្ញា។

ក៖ចាំ!!

ខ៖ទីបួនស្រីបានវាសនា។

ក៖ ពៅគេអាយុប៉ុន្មានដែរកូន?

ខ៖ហ៊ឹមិនដឹងប៉ុន្តែទេភ្លេចបាត់ហើយ!!

កះក្មេងដែរហោ?

ខះហ្នឹងហើយ!!

កះពូសំរាប់កូនពូទាំង៥នាក់ហ្នឹង ប៉ុន្មាននាក់មិញ?៨នាក់ហោ?

ខះ ៨ ។

កះ ពូមានអោយគាត់ទៅរៀនទេពូ?

ខះ ពួកហ្នឹងសុទ្ធតែរៀនចប់ហើយហ្នឹង។

កះចាំ!!អញ្ចឹងតែឥឡូវមានអ្នកខ្លះនៅរៀនដែរតើហីពូហោ?

ខះអត់មានទេ។

កះ គាត់ឈប់រៀនខ្លះហើយពូហោ?

ខះបាទ!!

កះពូគិតថាការសិក្សាម៉េចដែរបានពូអោយកូនទៅរៀនគ្រប់ៗគ្នាអីចឹងទៅណាស់?តើគិតថាល្អម៉េចដែរអីចឹងដែលពូជំរុញគាត់ទៅរៀនអញ្ចឹងណាស់?

ខះដើម្បីអនាគតខ្លួនគាត់ហ្នឹងហាំ!!

កះកុំអោយល្ងិតល្ងង់កុំអោយ ដឹងថាកាលយើងសម័យប៉ុល
ពតអញ្ចឹងទៅវារៀនវាមិនបានដិតដល់។

កះហ៊ីៗ!!

ខះរៀនរៀនអីចឹងទៅគេហៅអោយទៅទូលអាចមន៍គោទូអីអីចឹងទៅ!!!មិនដូចឥឡូវបានរៀនពេញៗ។

កះអីចឹងពូពេលនៅក្នុងជំនាន់ប៉ុល ពតគេអោយពូរៀនដែរតើហោ?

ខះ រៀនតើ!!រៀនដូចមិនរៀនអញ្ចឹង!!

កៈ ៣ឆ្នាំ៨ខែហ្នឹងគេអោយរៀនរហូតឬក៏ថារៀនចោះៗតែគេអោយរៀនរហូត?

ខៈ រៀនរហូតប៉ុន្តែ!!

(មិត្តភក្តិ)ៈប៉ុន្តែរៀនបានតែកុមារតូចៗហ្នឹង។

ខៈទូចៗ អាធំៗទូលអាចមន៍គោ កាប់ដីកាប់អីហ្នឹង!!

កៈចាំ!! គេអត់អោយម៉ងពូណេះ?

ខៈ ហ្នឹងហើយ។

កៈហើយគ្រូបង្រៀនហ្នឹងអ្នកណាគេវិញ ចេះអក្សរច្រើនទេ?

(មិត្តភក្តិ)ៈ វាអត់សូវចេះទេ!!

ខៈ វាចេះស្អី។

(មិត្តភក្តិ)ៈ វាអោយយើងអ្នកណាអត់ចេះអក្សរឆ្លើយថាអត់ចេះ
ហើយកាលហ្នឹងសុទ្ធតែរៀនថ្នាក់ធំៗម្នាក់ៗហាំ!!អញ្ចឹងហើយគេកាត់អាក្តារគរហ្មំ!!កាត់ដាក់ក្តារ
ប្រវែងប្រវែងហ្នឹងអោយដូចថាអោយយើងសរសេរអក្សរកបញ្ច្រាស់អញ្ចឹងទៅ
មែនអត់ហ៊ានធ្វើចេះទេ!!

កៈហ្ហំ!!!

(មិត្តភក្តិ)ៈចេះវ៉ៃចោលហើយ។

កៈហ្ហំ!!

(មិត្តភក្តិ)ៈហ្នឹងហើយអត់ហ៊ានធ្វើចេះទេ។

កៈ ធ្វើសរសេរ បើសិនជាអោយបង្រៀន បង្រៀនបញ្ច្រាស់?

(មិត្តភក្តិ)ៈ ហ្នឹងហើយយើងធ្វើអត់ចេះគូស។

ខៈហ្នឹងហើយ!!

(មិត្តភក្តិ)៖ ធ្វើដូចក្មេងគូសលេង។

ក៖ ហ្នំ!និយាយទៅពេលហ្នឹងធ្វើអត់ដឹងអីទាំងអស់ម៉ងពូណោះ?

ខ៖ ជំនាន់ហ្នឹងគ្រូបង្រៀនភាគច្រើនសុទ្ធតែអ្នកអត់ចេះអក្សរម៉ង!!

(មិត្តភក្តិ)៖ អត់ចេះអក្សរទេគ្រូបង្រៀនក៏អត់សូវចេះអក្សរដែរ!!!

ខ៖អត់ចេះអក្សរទេ!!

(មិត្តភក្តិ)៖ចេះតិចៗហ្នឹង!!

ក៖ ពិបាកណាស់អ៊ីចឹង!!

ខ៖ អានាក់ចេះហើយអានាក់អត់ចេះដូចគ្នាដឹងរៀនអាណាមើលអាណា!!

ក៖ ហើយអ៊ីចឹងទៅអាណាមើលអាណាអ៊ីចឹងមិនចេញមកអស់ហើយ?

(មិត្តភក្តិ)៖ កងអ្នកដែល អ្នកដែលនេះ អត់ចេះសោះម៉ង។

ក៖ ទៅធ្វើដឹកនាំគេម៉េចទៅបើអត់ចេះអ៊ីចឹង?ញ៉ុមឆ្ងល់ដែរ!!

(មិត្តភក្តិ)៖
គេបានសំដីគេដូចថាគេថាគេដូចថាគេនិយាយមកនិយាយខ្លាំងៗណាស់!!ដូចថាហ្អែងល្មមទៅធ្វើការហើយ ដូចថានៅបំបៅកូន
ដល់ម៉ោងហើយមិនរៀបចំខ្លួនទៅធ្វើការទេនៅបំបៅកូនអ៊ីចឹងថាអោយយើងម៉ាឈឺៗ។

ក៖ចាំ!!និយាយទៅបើសិនជាអ្នកណាគេអត់ស្ដាប់មានតែសម្លាប់ចោល។

(មិត្តភក្តិ)៖ អត់ស្ដាប់អត់បានទេ។

ក៖ សម្លាប់ចោលម៉ងអ៊ំហេ!!អញ្ចឹងលោកពូមួយនេះគឺជាសំនួរមួយចុងក្រោយហាំ
តើលោកពូមានពាក្យពេចន៍អីផ្ដែផ្ដាំកូនចៅជំនាន់ក្រោយអោយគាត់ដើរលើផ្លូវអីវ៉ាន់ម៉េចដែរ?

ខ៖ ចង់ផ្ដែផ្ដាំអោយក្មេងជំនាន់ក្រោយអោយគាត់ដើរផ្លូវល្អ។

ក៖ចា!!

ខ៖កុំអោយភ្លើតភ្លើនសេពគ្រឿងញៀនគ្រឿងអីអញ្ចឹងទៅណាស់។

ក៖ ហើយដូចជាអោយគាត់ដើរលើផ្លូវមួយដ៏ល្អអ៊ីចឹងទៅពូណោះ?

ខ៖បាទ!!

ក៖អ៊ីចឹងពូសំរាប់សព្វថ្ងៃហ្នឹង ពូនៅក្នុងភូមិព្រៃកហូរហ្នឹងរហូតហើយហោ?

ខ៖ បាទ!!

ក៖ពូអត់ចាំថាផ្លាស់ប្តូរមកប៉ុន្មានឆ្នាំហើយទេហោ?

ខ៖ ភ្លេចហើយ យូរហើយ ពីមុនញ៉ុមនៅនេះតាគ្គុលនេះ។

ក៖ ហើយបានប្តូរមកនៅព្រៃកហូរវិញ?

ខ៖បាទ!!

ក៖ពូមួយជីវិតរបស់ពូហាំ!!ញ៉ុមភ្លេចសួរកន្លែងមួយហ្នឹង
ពូធ្លាប់ធ្វើការងារអីគេខ្លះក្នុងមួយជីវិតហ្នឹងតាំងពីធំដឹងក្តីមកហាំ??

ខ៖ អត់ដែលធ្វើអីទេធ្វើតែកម្មករគេហ្នឹង។

ក៖អើរខាងការងារអីគេវិញពូកម្មករការងារអីគេវិញ?

ខ៖ កម្មករកាលស្របក់នោះញ៉ុមធ្វើតែការ៉ូ។

ក៖ ធ្វើអ្នករៀបការ៉ូពូហោ?

ខ៖ ធ្វើការ៉ូ អាការ៉ូគេផលិតការ៉ូម៉ងហាំ!!

ក៖ គេមានរោងចក្រគេម៉ងពូហោ?

ខ៖ អត់ទេតដ្ឋការ៉ូយើងហ្នឹង។

(មិត្តភក្តិ)៖ គេធ្វើអាតដ្ឋការ៉ូគេម៉ងហោ?

ខ៖ បាទ!!

ក៖ នៅឯណាវិញពូ?

ខ៖នៅភ្នំពេញបានមាន។

(មិត្តភក្តិ)៖ ចាក់ពុម្ព។

ក៖ហ្ហ៎!!

ខ៖ ក្រោយពេងកុនគីរីរម្យខ្វះអី។

ក៖ ចាំ!!អញ្ចឹងកាលពីសម័យមុនពូហោ?

ខ៖ បាទ!!

ក៖ចុះដល់ពេលឈប់ពីអាហ្នឹងមកពូធ្វើអីគេទៀត?

ខ៖ ឈប់ពីអាហ្នឹងមករត់ការកង់បីរត់អីហ្នឹង។

ក៖ ចាំហើយដល់ពេលឥឡូវហ្នឹងមកក៏ឈប់នៅផ្ទះសិនទៅពូណោះ?

ខ៖ ហ្នឹងហើយ។

ក៖ហ្នឹងហើយពូមានអីចង់និយាយបន្ថែមអីគេទៀតអញ្ចឹងណាស់?

ខ៖ អត់អីទេ ប៉ុណ្ណឹងបាទ!!

ក៖ហ្នឹងហើយ
អញ្ចឹងអរគុណច្រើនលោកពូសំរាប់ការរៀបរាប់ពីជីវិតលោកពូដែលបានក្បោះក្បាយហើយអ្វីទាំងអស់ហ្នឹងគឺកូនចៅរបស់លោកពូគាត់នឹងបានស្តាប់ថាលោកពូនឹងឆ្លងកាត់នឹងរឿងអីគេខ្លះអ៊ីចឹងទៅណាស់ដោយសារលោកពូអត់សូវសំលេងបានអ៊ីចឹងអត់បាននិយាយទាំងអស់តែគាត់ក៏ដូចបានស្តាប់ខ្លះៗពីជីវប្រវត្តិរបស់លោកពូសង្ខេបៗអ៊ីចឹងដែរ
ចាំអញ្ចឹងសំរាប់ពេលនេះអរគុណណាស់លោកពូ។

ខ៖ បាទបាទ!!

ក៖ ចាំៗ